# ព្រឹទ្ធសភា

# SENATE MAGAZINE

## ទស្សនាវដ្តីប្រចាំខែសីហា




លេខ ២៧៤ ឆ្នាំទី២៣ ពុទ្ធសករាជ ២៥៦៧ គ្រិស្តសករាជ ២០២៣

Issue 274 Volume 23 Before Christ 2567 Common Era 2023

# មាតិកា

## សកម្មភាពថ្នាក់ដឹកនាំ




- សម្ដេចប្រធានព្រឹទ្ធសភា អនុញ្ញាតឱ្យឯកអគ្គរាជទូតកម្ពុជាទើបតែងតាំងថ្មី ចូលជួបសម្ដែងការគួរសម និងទទួលអនុសាសន៍ ........................................................ ១
- ឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា ដឹកនាំគណៈប្រតិភូសភាកម្ពុជា ចូលរួមមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៤ .................................................................................... ៣
- ថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ........................................................................៧


## សកម្មភាពគណៈកម្មការ




- សាស្ត្រាចារ្យ និងនិស្សិត នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចមកទស្សនកិច្ចសិក្សាឈ្វេងយល់អំពីព្រឹទ្ធសភា.......................... ៨
- គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា ........................................ ១០
- ការងារទទួលពាក្យបណ្ដឹង..........................................................................................................១២
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្ដាភូមិភាគទាំង៨........................................................ ១៣
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស ............................................................................. ២២
- សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ .............................................................................................២៣


## សកម្មភាពអគ្គលេខាធិការដ្ឋាន




- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកក្កដា និងទិសដៅការងារខែសីហា ឆ្នាំ២០២៣........................................................... ២៤
- ឯកឧត្តម អ៊ុំ សារឹទ្ធ ណែនាំដល់និស្សិតជ័យលាភីអាហារូបករណ៍ JDS ឱ្យគោរពច្បាប់ប្រទេស និងសាលា ព្រមទាំងផ្សាយអំពីការអភិវឌ្ឍប្រទេសជាតិ................................................. ២៥
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រជុំផ្សព្វផ្សាយការត្រៀមខ្លួនរបស់ព្រឹទ្ធសភា ដើម្បីចូលនីតិកាលថ្មី ..................... ២៧
- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ ...........................................................២៨



**អ្នកគ្រប់គ្រងទូទៅ**
ឯកឧត្តម អ៊ុំ សារឹទ្ធ

**អ្នកសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធ**
ឯកឧត្តម លឹម ប៊ុនហុក
ឯកឧត្តម កែវ ចាន់ណា
ឯកឧត្តម សុខ រិទ្ធី
ឯកឧត្តម គឹម ពិសិដ្ឋ
ឯកឧត្តម ជួន ណា
លោក ជួន សុខជី
លោក ទេព មករា
លោក កុក វ៉ៃ

**អ្នកគ្រប់គ្រងផ្ទាល់**
លោក ទេព មករា

**ក្រុមអ្នកយកព័ត៌មាន**
ការិយាល័យព័ត៌មាន

**ការីកុំព្យូទ័រ**
លោក ជុំ ច័ន្ទរតនា
លោក ធុន គីមជី
លោក គិន ប៉ាត់ថាមីរ


*ក្របមុខ ៖ សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ថតរូបអនុស្សាវរីយ៍ជាមួយឯកអគ្គរាជទូតកម្ពុជា។*
*ក្របក្រោយ ៖ ទេសភាពអគារក្រហមវិមានព្រឹទ្ធសភា។*


**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**
**វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**
**ទូរស័ព្ទ: (855) 23 211441, 211442, 211443, ទូរសារ: (855) 23 211446**
**E-mail : oumsarith.sgsenate@gmail.com**
**Website: www.senate.gov.kh**
**www.elibrary.senate.gov.kh**
**Facebook: www.facebook.com/senateofcambodia**

# សម្ដេចប្រធានព្រឹទ្ធសភា អនុញ្ញាតឱ្យឯកអគ្គរាជទូតកម្ពុជាទើបតែងតាំងថ្មី ចូលជួបសម្ដែងការគួរសម និងទទួលអនុសាសន៍



*សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា*

នាព្រឹកថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣ នៅវិមានព្រឹទ្ធសភា សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជាទើបតែងតាំងថ្មីចំនួន៧រូប ចូលជួបសម្ដែងការគួរសម និងទទួលអនុសាសន៍ មុនពេលអញ្ជើញទៅបំពេញបេសកកម្មការទូតប្រចាំនៅប្រទេសជាមិត្តនានា។ ឯកអគ្គរាជទូតទាំង៧រូបនោះ រួមមាន៖

១-ឯកឧត្តម **លុយ ដាវីត** ឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋបារាំង ប្រទេសអ៊ីតាលី ប្រទេសព័រទុយហ្គាល់ ប្រទេសម៉ាល់តា ព្រះរាជាណាចក្រអេស្ប៉ាញ ប្រទេសបូរីក្សត្រអង់ដរ និងប្រទេសបូរីក្សត្រម៉ូណាកូ។

២-ឯកឧត្តម **ឡាយ សំកុល** ឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅចក្រភពអង់គ្លេស ប្រទេសអៀរឡង់ ព្រះរាជាណាចក្រដាណឺម៉ាក ប្រទេសស៊ុយអែត ប្រទេសន័រវែស និងសាធារណរដ្ឋហ្វាំងឡង់។

៣-ឯកឧត្តម **សុភ ខា** ឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋតួកគី ប្រទេសតាហ្ស៊ីគីស្ថាន ប្រទេសអាស៊ែបៃហ្សង់ ប្រទេសកាហ្សាក់ស្ថាន ប្រទេសហ្សកហ្ស៊ី ប្រទេសកៀហ្ស៊ីស៊ីស្ថាន សាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន និងប្រទេសរដ្ឋអ៊ីស្រាអែល។

៤-ឯកឧត្តម **ទាន សំណាង** ឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើត។

៥-ឯកឧត្តម **ហ៊ុលគ្រុង ផាណាង** ឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

៦-ឯកឧត្តម **ឈាង ធីរ៉ា** ឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ សាធារណរដ្ឋប៉ូឡូញ សាធារណរដ្ឋឆែក សាធារណរដ្ឋក្រូអាត សាធារណរដ្ឋហុងគ្រី សាធារណរដ្ឋស្លូវ៉ាគី សាធារណរដ្ឋស្លូវេនី និងប្រទេស





*ឯកអគ្គរាជទូតកម្ពុជា ចូលជួបសម្ដែងការគួរសម និងទទួលអនុសាសន៍*

អ៊ុយក្រែន។

៧-ឯកឧត្តម **តាន់ ម៉ុនចាំ** ឯកអគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋស៊ែប៊ី។

នៅក្នុងឱកាសនោះ សម្តេចប្រធានព្រឹទ្ធសភា បានសម្តែងនូវការអបអរសាទរចំពោះឯកឧត្តមទាំង៧រូបដែលត្រូវបានព្រះមហាក្សត្រតែងតាំងជាឯកអគ្គរាជទូតប្រចាំប្រទេសជាមិត្តនានា។ ការទៅបំពេញភារកិច្ចដ៏ខ្ពង់ខ្ពស់នាពេលនេះស្របពេលនឹងការវិវឌ្ឍថ្មីនៅព្រះរាជាណាចក្រកម្ពុជាយើង ដែលរដ្ឋសភាទើបតែបានបើកសម័យប្រជុំដំបូង នីតិកាលទី៧ ក្រោមព្រះរាជអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ហើយរាជរដ្ឋាភិបាលថ្មី នីតិកាលទី៧ នៃរដ្ឋសភា ដឹកនាំដោយឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត **ហ៊ុន ម៉ាណែត** ជានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាទើបតែតែងតាំងឡើងជាផ្លូវការ។ ជាមួយគ្នានេះ សម្តេចបានផ្តាំផ្ញើចំពោះឯកឧត្តមឯកអគ្គរាជទូតទាំង៧រូបត្រូវយកចិត្តទុកដាក់ពង្រឹងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការឱ្យបានល្អប្រសើរ ដើម្បីផលប្រយោជន៍ ទៅវិញទៅមករវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសជាមិត្តដែលខ្លួនតាំងនៅទាំងពេលបច្ចុប្បន្ន និងតទៅអនាគតយូរអង្វែង។ ដើម្បីសម្រេចគោលបំណងនេះ ត្រូវយកចិត្តទុកដាក់កសាងទំនាក់ទំនងល្អជាមួយនឹងបណ្តាស្ថាប័ន និងជាមួយប្រជាជន នៃប្រទេសនីមួយៗឱ្យបានល្អប្រសើរ។

ទន្ទឹមនឹងនេះ ត្រូវយកចិត្តទុកដាក់គិតគូរដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋខ្មែរ និងពលករខ្មែរដែលកំពុងរស់នៅប្រកបអាជីវកម្ម និងធ្វើការងារនៅប្រទេសដែលខ្លួនតាំងនៅ។ ជានិច្ចកាលត្រូវបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយនឹងឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត នៃប្រទេសនានាប្រចាំនៅប្រទេសដែលខ្លួនតាំងនៅ។

សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** បានផ្តល់អនុសាសន៍សំខាន់ៗមួយចំនួនជូនដល់ឯកឧត្តមឯកអគ្គរាជទូត ទាំងអស់ត្រូវសកម្មផ្សព្វផ្សាយ និងបកស្រាយពន្យល់អំពីសភាពការណ៍ពិត និងការអនុវត្តនូវលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាជូនដល់សាធារណមតិជាតិ និងអន្តរជាតិ ជាពិសេសនៅប្រទេសដែលខ្លួនកំពុងបំពេញភារកិច្ច ដោយត្រូវផ្តល់ព័ត៌មានឱ្យបានរហ័ស ចំពោះសភាពការណ៍ជាក់ស្តែងរបស់កម្ពុជា និងត្រូវយកចិត្តទុកដាក់ផ្សព្វផ្សាយក្នុងការទាក់ទាញវិនិយោគិន និងភ្ញៀវទេសចរបរទេសមកទស្សនាកម្ពុជាឱ្យបានកាន់តែច្រើន ព្រមទាំងសកម្មផ្សព្វផ្សាយអំពីវប្បធម៌ប្រពៃណី និងទំនៀមទម្លាប់ដ៏ល្អរបស់កម្ពុជាយើង។

ក្នុងឱកាសនោះដែរ ឯកឧត្តម **លុយ ដាវីត** ជាតំណាងឯកអគ្គរាជទូតទាំងអស់បានប្តេជ្ញានៅចំពោះមុខ សម្តេចប្រធានព្រឹទ្ធសភាថា នឹងខិតខំបំពេញភារកិច្ចការទូតប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ឱ្យបានស័ក្តិសមជាតំណាងឱ្យព្រះរាជាណាចក្រកម្ពុជា នៅលើឆាកអន្តរជាតិ។

ឯកឧត្តមឯកអគ្គរាជទូតទាំងអស់បានសន្យាថា នឹងខិតខំអនុវត្តតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចប្រធានព្រឹទ្ធសភា និងខិតខំផ្សព្វផ្សាយអំពីវឌ្ឍនភាព និងការរីកចម្រើនរបស់ប្រទេសជាតិ ពង្រឹងពង្រីកទំនាក់ទំនងសហប្រតិបត្តិការល្អប្រសើរជាមួយនឹងប្រទេសម្ចាស់ផ្ទះ និងឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូតប្រទេសផ្សេងៗទៀត ព្រមទាំងខិតខំទាក់ទាញវិនិយោគិន និងអ្នកទេសចរឱ្យមកកម្ពុជាបានកាន់តែច្រើន ដើម្បីរួមចំណែកអភិវឌ្ឍប្រទេសជាតិ និងលើកកម្ពស់កិត្យានុភាពជាតិនៅក្នុងក្របខ័ណ្ឌតំបន់ និងលើពិភពលោក៕

(អត្ថបទ៖ នុត សច្ចៈ និងរូបភាព៖ គង់ យ៉ារីន)



# ឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា ដឹកនាំគណៈប្រតិភូសភាកម្ពុជា ចូលរួមមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៤




*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អញ្ជើញចូលរួមមហាសន្និបាត អន្តរសភាអាស៊ានលើកទី៤៤*

ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ ព្រឹទ្ធសភា បានអញ្ជើញដឹកនាំគណៈប្រតិភូសភា នៃព្រះរាជាណាចក្រកម្ពុជា ចូលរួមមហាសន្និបាតអន្តរសភាអាស៊ាន លើកទី៤៤ ក្រោមមូលបទ "ការឆ្លើយតបរបស់សភា ដើម្បីស្ថិរភាព និងវិបុលភាពអាស៊ាន" នៅរដ្ឋធានីហ្សាការតា នៃសាធារណរដ្ឋឥណ្ឌូណេស៊ី ចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣។

មហាសន្និបាតអាយប៉ាលើកទី៤៤ មានការចូលរួមពីសភាសមាជិកអាយប៉ាចំនួន៩ប្រទេស រួមមានប្រទេស៖ ព្រុយណេ កម្ពុជា ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ឡាវ ហ្វីលីពីន សិង្ហបុរី ថៃ និងវៀតណាម ព្រមទាំងមានសភាប្រទេសសង្កេតការណ៍ចំនួន១៥ប្រទេស និងអង្គការ/ស្ថាប័ន ជាភ្ញៀវ នៃសភាម្ចាស់ផ្ទះ សរុបចំនួន៥៥៦រូប។




*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន ចូលរួមពិធីបើកជាផ្លូវការ នៃមហាសន្និបាតអាយប៉ាលើកទី៤៤*

ក្នុងឱកាសចូលរួមមហាសន្និបាតនេះ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិ នៃមហាសន្និបាតអាយប៉ាលើកទី៤៤ និងបានដឹកនាំគណៈប្រតិភូសភាកម្ពុជា ចូលរួមពិធីបើកជាផ្លូវការ នៃមហាសន្និបាតអាយប៉ាលើកទី៤៤ ក្រោមអធិបតីភាពលោកជំទាវបណ្ឌិត **ពាន់ ម៉ាហារ៉ានី** (Puan Maharani) ប្រធានរដ្ឋសភា នៃសាធារណរដ្ឋឥណ្ឌូណេស៊ី និងជាប្រធានមហាសន្និបាតអាយប៉ាលើកទី៤៤។ ព្រមទាំងបានអញ្ជើញចូលរួមក្នុងសម័យប្រជុំលើកទី១ នៃមហាសន្និបាតអាយប៉ាលើកទី៤៤។




*គណៈប្រតិភូសភាកម្ពុជា ថតរូបអនុស្សាវរីយ៍ក្នុងឱកាសបើក មហាសន្និបាត AIPA លើកទី៤៤*

ក្នុងឱកាសនោះ ឯកឧត្តមកិត្តិសង្គហបណ្ឌិតបានអញ្ជើញឡើងថ្លែងសុន្ទរកថា ស្តីពីការឆ្លើយតបរបស់សភា ដើម្បីស្ថិរភាព និងវិបុលភាពអាស៊ាន ដោយបានវាយតម្លៃខ្ពស់ចំពោះមូលបទ ដែលឆ្លើយតបទៅនឹងស្ថានភាពវិវឌ្ឍជាក់ស្តែងនៅក្នុងតំបន់ និងពិភពលោក និងបានបញ្ជាក់កិច្ចខិតខំប្រឹងប្រែង និងការប្តេជ្ញាចិត្តដ៏មោះមុតរបស់កម្ពុជាចំពោះការឯកភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការដ៏




*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អញ្ជើញឡើងថ្លែងសុន្ទរកថា ក្នុងសម័យប្រជុំលើកទី១១ AIPA-៤៤*

រឹងមាំ ក្នុងចំណោមបណ្តាប្រទេសជាសមាជិកអាស៊ាននិងដៃគូរអាស៊ានទាំងអស់ ក្នុងស្មារតីសហប្រតិបត្តិការ ភាពបើកចំហ ពហុភាគីនិយម សំដៅកសាងនិម្មាបនកម្មតំបន់ប្រកបដោយសន្តិភាព ស្ថិរភាព និងវិបុលភាព។

ឯកឧត្តមកិត្តិសង្គហបណ្ឌិត បានលើកឡើងអំពីការដើរតួនាទីសំខាន់របស់អាយប៉ា ក្នុងការចូលរួមលើកកម្ពស់សន្តិភាព ស្ថិរភាព និងវឌ្ឍនភាពសេដ្ឋកិច្ចក្នុងតំបន់អាស៊ាន ការតភ្ជាប់ទំនាក់ទំនងរវាងប្រជាជន និងប្រជាជន និងការសម្រេចបាននូវជោគវាសនារួមរបស់អាស៊ាន និងគោលដៅសហគមន៍អាស៊ានឆ្នាំ២០២៥។

ជាមួយគ្នានោះ ឯកឧត្តមកិត្តិសង្គហបណ្ឌិត បានជម្រាបមហាសន្និបាតអំពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ នៃរដ្ឋសភារបស់កម្ពុជា កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ប្រកបដោយជោគជ័យ ស្របតាមគោលការណ៍គ្រឹះ នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស យុត្តិធម៌ ត្រឹមត្រូវ ស្មើភាព បរិយាបន្ន និងសន្តិភាព ដោយមានអ្នកសង្កេតការណ៍ជាតិ-អន្តរជាតិចូលរួមសង្កេតការណ៍ជាច្រើនពាន់នាក់ និងមានអត្រាប្រជាជនចេញទៅបោះឆ្នោតខ្ពស់(៨៤,៥៨%) នៃចំនួនប្រជាជនដែលមានក្នុងបញ្ជីបោះឆ្នោត។

សូមជម្រាបថា ក្នុងសម័យប្រជុំលើកទី១ នៃមហាសន្និបាតអាយប៉ាលើកទី៤៤ ក្រៅពីប្រធានគណៈប្រតិភូសភាកម្ពុជា ក៏មានការអញ្ជើញឡើងថ្លែងសុន្ទរកថាដោយប្រធានគណៈ-ប្រតិភូ នៃសភាសមាជិកអាយប៉ាទាំង៩ផ្សេងទៀត ក៏ដូចជា ប្រធានគណៈប្រតិភូប្រទេសសង្កេតការណ៍ អគ្គលេខាធិការអាស៊ាន អគ្គលេខាធិការអាយប៉ា និងភ្ញៀវ នៃសភាម្ចាស់ផ្ទះផងដែរ។

ក្រៅពីនេះ គណៈប្រតិភូសភាកម្ពុជាបានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការ និងកិច្ចប្រជុំពាក់ព័ន្ធនានា នៃមហាសន្និបាតអាយប៉ាលើកទី៤៤ រួមមាន៖ កិច្ចប្រជុំគណៈ-កម្មាធិការសភាស្ត្រីអាយប៉ា (WAIPA) កិច្ចប្រជុំគណៈកម្មា-ធិការនយោបាយ កិច្ចប្រជុំគណៈកម្មាធិការសេដ្ឋកិច្ច កិច្ច-ប្រជុំគណៈកម្មាធិការសង្គមកិច្ច កិច្ចប្រជុំគណៈកម្មាធិការរៀបចំ កិច្ចប្រជុំគណៈកម្មាធិការសភាវ័យក្មេង (YPA) កិច្ចប្រជុំគណៈកម្មាធិការបូកសរុប ជំនួបសវនាការអាស៊ាន-អាយប៉ា (ASEAN-AIPA Hearing)។














គណៈប្រតិភូសភាកម្ពុជា បានអញ្ជើញចូលរួមកិច្ចសន្ទនាជាមួយនឹងបណ្តាប្រទេសសង្កេតការណ៍អាយប៉ា ចំនួន១៥ ប្រទេស រួមមានប្រទេស៖ អូស្ត្រាលី អាស៊ែបៃហ្សង់ បេឡារុស កាណាដា ចិន សភាអឺរ៉ុប ហុងគ្រី ជប៉ុន កូរ៉េ ម៉ារ៉ុក ន័រវែស រុស្ស៊ី ទីម័រឡេស្តេ អ៊ុយក្រែន និងសហរដ្ឋអាមេរិក ក្រោមមូលបទ "ការប្តេជ្ញាចិត្តរួមគ្នា ដើម្បីសន្តិភាព ស្ថិរភាព និងវិបុលភាព"។






*គណៈប្រតិភូសភាកម្ពុជា អញ្ជើញ ចូលរួមសម័យប្រជុំលើកទី២ និងពិធីបិទAIPA-៤៤*




បន្ទាប់មក គណៈប្រតិភូសភាកម្ពុជា ដឹកនាំដោយឯកឧត្តមកិត្តិសង្គហបណ្ឌិត **ឆេង ខន** បានអញ្ជើញចូលរួមសម័យប្រជុំពេញអង្គលើកទី២ និងពិធីបិទមហាសន្និបាត ដោយមានការអនុម័តរបាយការណ៍របស់គណៈកម្មាធិការនានា និងចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍រួម (Joint Communique) នៃមហាសន្និបាតអាយប៉ាលើកទី៤៤។

សូមជម្រាបថា មហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៥ សភា នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នឹងធ្វើជាម្ចាស់ផ្ទះរៀបចំ នៅរដ្ឋធានី វៀងចន្ទន៍ ចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៤។



*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន ជួបពិភាក្សាជាមួយ ឯកឧត្តម វឿង ឌីញហ្វេ ប្រធានរដ្ឋសភាវៀតណាម*



*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន ជួបពិភាក្សាជាមួយ លោកជំទាវ សួនថន សាយ៉ាចក អនុប្រធានរដ្ឋសភាឡាវ*

ក្រៅពីចូលរួមមហាសន្និបាត ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាជាមួយនឹងគណៈប្រតិភូ នៃប្រទេសជាមិត្ត រួមមាន៖ ជំនួបពិភាក្សាទ្វេភាគីជាមួយនឹងសភាវៀតណាម ដឹកនាំដោយឯកឧត្តម **វឿង ឌីញហ្វេ** ប្រធានរដ្ឋសភាវៀតណាម។ ជំនួបពិភាក្សាទ្វេភាគីជាមួយនឹងរដ្ឋសភាឡាវ ដឹកនាំដោយលោកជំទាវ **សួនថន សាយ៉ាចក** អនុប្រធានរដ្ឋសភាឡាវ។ ជំនួបពិភាក្សាទ្វេភាគីជាមួយនឹងសភាតំណាងប្រជាជនចិន នៃសាធារណរដ្ឋប្រជាមានិតចិន ដឹកនាំដោយឯកឧត្តម ZHU YONGGUAN សមាជិកសភាតំណាងប្រជាជនចិន នៃសាធារណរដ្ឋប្រជាមានិតចិន និងជាប្រធានគណៈប្រតិភូចិន ដែលជាប្រទេសសង្កេតការណ៍អាយប៉ា។

តាមរយៈមហាសន្និបាតអាយប៉ាលើកទី៤៤ បានអនុម័តសេចក្តីសម្រេចសរុបចំនួន៣០ របស់គណៈកម្មាធិការនានា ដែលបានឆ្លុះបញ្ចាំងការប្តេជ្ញាចិត្តក្នុងការដោះស្រាយបញ្ហាប្រឈមតំបន់ដែលជាកង្វល់រួម និងការពង្រឹងសាមគ្គីភាពឯកភាពអាស៊ាន និងការកសាងសហគមន៍អាស៊ានប្រកបដោយភាពធន់ និងចីរភាព ព្រមទាំងបានទទួលសភាសង្កេតការណ៍ថ្មីបន្ថែមចំនួន៣ រួមមាន៖ រដ្ឋសភាអំណាចប្រជាជន នៃសាធារណរដ្ឋគុយបា រដ្ឋសភា នៃសាធារណរដ្ឋតួកគី និងរដ្ឋសភា នៃសាធារណរដ្ឋអាមេនី។

ក្រៅពីនេះ មហាសន្និបាតអាយប៉ាលើកទី៤៤ ក៏បានអនុម័តជាឯកច្ឆន្ទលើការដំឡើងការបង់វិភាគទានប្រចាំឆ្នាំរបស់សភាជាសមាជិកអាយប៉ា និងការអនុវត្តការបង់វិភាគទានប្រចាំឆ្នាំ សម្រាប់សភាសង្កេតការណ៍អាយប៉ានីមួយៗ។ ដោយឡែក ចំពោះគម្រោងបណ្ណាល័យឌីជីថលអាយប៉ា ដែលជាគំនិតផ្តួចផ្តើមរបស់សភាកម្ពុជា មហាសន្និបាតបានអនុម័តបង្កើតឱ្យមានក្រុមការងារ ដើម្បីបន្តពិភាក្សាលើការបង្កើតបណ្ណាល័យឌីជីថលអាយប៉ា៕

(អត្ថបទ៖ ទេព មករា និងរូបភាព៖ ខុទ្ទកាល័យអនុប្រធានទី២)



*ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន ថតរូបអនុស្សាវរីយ៍ជាមួយ គណៈប្រតិភូ នៃសាធារណរដ្ឋប្រជាមានិតចិន*

## សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ និងចូលរួមពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៣ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **សំ ព្រហ្មនា** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ នៅផ្ទះលេខ៩ ផ្លូវលេខ៥៦៨ ភូមិ៣ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។




❈នាព្រឹកថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** អនុប្រធានទី១ព្រឹទ្ធសភា ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា និងឯកឧត្តម លោកជំទាវប្រធានគណៈកម្មការទាំង១០ នៃព្រឹទ្ធសភា បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបើកសម័យប្រជុំដំបូងរដ្ឋសភា នីតិកាលទី៧ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានរដ្ឋសភា។




❈នៅថ្ងៃទី២ ខែសីហា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** អនុប្រធានទី១ព្រឹទ្ធសភា និងលោកជំទាវ បាននាំយកទៀនចំណាំព្រះវស្សា ទេយ្យវត្ថុគ្រឿងឧបភោគ បរិភោគ និងបច្ច័យមួយចំនួន ទៅប្រគេនព្រះសង្ឃគង់ចាំព្រះវស្សាចំនួន២វត្ត គឺវត្តទេពនិម្មិត ហៅ(វត្តអញ្ចាញ) ស្ថិតនៅឃុំក្របៅ ស្រុកកំចាយមារ និងវត្តពង្សរង្សី ហៅ(វត្តជ្រៃម្រាក់) ស្ថិតនៅឃុំគោកគង់កើត ស្រុកកញ្ច្រៀច ខេត្តព្រៃវែង៕



# សាស្ត្រាចារ្យ និងនិស្សិត នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចមកទស្សនកិច្ចសិក្សាឈ្វេងយល់អំពីព្រឹទ្ធសភា



*ឯកឧត្តម ម៉ាន់ ឈឿន អញ្ជើញធ្វើបទបង្ហាញ*

នាព្រឹកថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៣ សាស្ត្រាចារ្យ និងនិស្សិត នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចចំនួន៨០នាក់ បានអញ្ជើញមកទស្សនកិច្ចសិក្សាឈ្វេងយល់អំពីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា។

ក្នុងដំណើរទស្សនកិច្ចសិក្សានេះ ត្រូវបានឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា អញ្ជើញមកទទួលបដិសណ្ឋារកិច្ច និងធ្វើបទបង្ហាញអំពីរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា រួមជាមួយគ្នានោះ លោក **ឃិន យូរ៉ាន់** អគ្គនាយករង នៃអគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី បានធ្វើបទបង្ហាញអំពីដំណើរការនីតិកម្មរបស់ព្រឹទ្ធសភា និងលោកស្រី **ឃុន សុវណ្ណនេត្រា** ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស បានធ្វើបទបង្ហាញអំពី រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

ក្នុងឱកាសនោះ ឯកឧត្តម **ម៉ាន់ ឈឿន** បានមានប្រសាសន៍ថា ប្រទេសកម្ពុជាមានសច្ចធម៌ប្រវត្តិសាស្ត្រ គឺមានសន្តិភាព និងមានការអភិវឌ្ឍ។ ក្នុងនោះ សាវតាររបស់ព្រឹទ្ធសភា មានតាំងពីនីតិកាលទី១ ដល់នីតិកាលទី៤ នីតិកាលនីមួយៗរបស់ព្រឹទ្ធសភាមានអាណត្តិ៦ឆ្នាំ សមាជិកព្រឹទ្ធសភាត្រូវចាត់តាំងខ្លះ និងត្រូវជ្រើសតាំងខ្លះ និងដោយការបោះឆ្នោតអសកល។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច៤០ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាបាន។

ឯកឧត្តមបានបន្តទៀតថា ព្រឹទ្ធសភាមានគណៈកម្មការជំនាញចំនួន១០ មានតួនាទី ភារកិច្ចជាសេនាធិការឱ្យព្រឹទ្ធសភា ដើម្បីជួយជ្រោមជ្រែងព្រឹទ្ធសភា ក្នុងការតាក់តែង និងប្រតិបត្តិច្បាប់ឱ្យកាន់តែមានភាពល្អប្រសើរឡើង និងចូលរួមចំណែកជំរុញឱ្យការអនុវត្តគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការនៅកម្ពុជាកាន់តែមានសន្ទុះរីកចម្រើន





*ទិដ្ឋភាពរួមក្នុងពិធីធ្វើបទបង្ហាញ*



ឯកឧត្តម ម៉ាន់ ឈឿន ថតរូបអនុស្សាវរីយ៍ជាមួយសាស្ត្រាចារ្យ និងនិស្សិត នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

ថែមទៀត ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងការគ្រប់គ្រងសេដ្ឋកិច្ច សង្គម វប្បធម៌ ឱ្យប្រព្រឹត្តទៅដោយសមធម៌ មានតម្លាភាព និងគណនេយ្យភាពយ៉ាងពិតប្រាកដ។

ឯកឧត្តមបានបញ្ជាក់ថា ព្រឹទ្ធសភាមានមុខងារស្នូលចំនួន៣ គឺមុខងារនីតិកម្ម មុខងារជាតំណាង និងមុខងារត្រួតពិនិត្យ និងតាមដានការអនុវត្តច្បាប់។ ក្រៅពីនេះ ព្រឹទ្ធសភាមានមុខងារគាំទ្រចំនួន២ទៀត គឺមុខងារសហប្រតិបត្តិការអន្តរជាតិ និងមុខងារអភិវឌ្ឍស្ថាប័ន។

បន្ទាប់ពីស្តាប់ការធ្វើបទបង្ហាញទាំងបីខាងលើរួចមក សាស្ត្រាចារ្យ និងនិស្សិត នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានអញ្ជើញទស្សនាកន្លែងធ្វើការសំខាន់ៗរបស់ព្រឹទ្ធសភា៖ សាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងអគារនានា នៅក្នុងបរិវេណវិមានព្រឹទ្ធសភា។

សូមបញ្ជាក់ថាវិមានព្រឹទ្ធសភា ជាអតីតវិមានរដ្ឋចំការមន គឺជាទីកន្លែងសម្រាប់ទទួលបដិសណ្ឋារកិច្ចប្រមុខរដ្ឋ នៃប្រទេសនានា ជាកន្លែងធ្វើការ និងជាព្រះរាជដំណាក់របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះរាជដំណាក់របស់ព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** និងព្រះរាជដំណាក់របស់ព្រះរាជបុត្រីព្រះរៀម **នរោត្តម បុប្ផាទេវី** ។ បច្ចុប្បន្នវិមានរដ្ឋចំការមន គឺជាកន្លែងធ្វើការរបស់ស្ថាប័នកំពូលៗចំនួន៣ គឺព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ និងឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម៕

(អត្ថបទ៖ អ៊ុក ប៉ូលីន និងរូបភាព៖ គង់ យ៉ារីន)





# គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា

❈ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជា ចេដ្ឋ** ប្រធានគណៈ-កម្មការទី២ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖



-កិច្ចប្រជុំរវាងគណៈកម្មការទី២ព្រឹទ្ធសភាជាមួយគណៈ-កម្មការកសាងផែនការយុទ្ធសាស្ត្រ៣ឆ្នាំរំកិល (ឆ្នាំ២០២៤-២០២៦) និងគម្រោងថវិកាប្រចាំឆ្នាំ២០២៤ នៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ដើម្បីពិនិត្យ និងពិភាក្សាលើគម្រោងថវិកាឆ្នាំ២០២៤របស់ព្រឹទ្ធសភា នាថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០២៣ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។



-កិច្ចប្រជុំរវាងគណៈកម្មការទី២ព្រឹទ្ធសភាជាមួយនឹងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដឹកនាំដោយឯកឧត្តម **ចាន់ សុធី** រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងពិភាក្សាលើគម្រោងថវិកាប្រចាំឆ្នាំ២០២៤របស់ព្រឹទ្ធសភា នាថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ នៅសាល-សិក្ខាសាលាបណ្ណាល័យ វិមានព្រឹទ្ធសភា។

-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី២ព្រឹទ្ធសភា នាព្រឹកថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣ ដើម្បី៖

**១**-ពិភាក្សាអំពីការងារត្រៀមចុះបេសកកម្មរបស់គណៈ-



កម្មការនៅចន្លោះសម័យប្រជុំព្រឹទ្ធសភា

**២**-ថវិការបស់គណៈកម្មការ និង

**៣**-បញ្ហាផ្សេងៗ។



❈នាព្រឹកថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា ឯកឧត្តម **ម៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា និង ឯកឧត្តម **ច្រឹង គឹមស្រ៊ាន** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអនុញ្ញាតឱ្យលោក Kansuke Otani អតីតសមាជិកសភាប្រចាំខេត្តហ៊ីយ៉ូហ្គូ ប្រទេសជប៉ុន បច្ចុប្បន្នជាប្រធាន Japan Asia Exchange Center និងក្រុមការងារយុវជនរបស់ឯកឧត្តមរដ្ឋមន្ត្រី Nishmura ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារពាក់ព័ន្ធនឹងវិស័យជាសមត្ថ-កិច្ចរបស់គណៈកម្មការ រួមមាន៖ ផែនការ វិនិយោគកសិកម្ម ធនធានទឹក ឧតុនិយម អភិវឌ្ឍន៍ជនបទ និងបរិស្ថាន ដើម្បីនាំយកនូវសំណូមពររបស់ភាគីកម្ពុជា ទៅរាយការណ៍ជូនតាមបណ្តាក្រសួងដែលមានការពាក់ព័ន្ធនៅក្នុងប្រទេសជប៉ុន ឱ្យមកបណ្តាក់ទុនវិនិយោគនៅកម្ពុជា

តាមវិស័យដែលពាក់ព័ន្ធឱ្យបានកាន់តែច្រើន នៅសាល-ប្រជុំគណៈកម្មការទី៣ព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣ នៅសាល-ប្រជុំគណៈកម្មការទី៥ព្រឹទ្ធសភា លោកជំទាវកិត្តិនីតិកោសល បណ្ឌិត **ឌី ម៉ូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៥ព្រឹទ្ធសភា ដើម្បីពិនិត្យ និងពិភាក្សាលើ៖

១-ការបូកសរុបរបាយការណ៍សកម្មភាពការងារគណៈ-កម្មការប្រចាំខែសីហា ឆ្នាំ២០២៣

២-ការបូកសរុបចំណូល-ចំណាយថវិកាប្រចាំខែសីហា ឆ្នាំ២០២៣

៣-របាយការណ៍គណៈប្រតិភូទៅប្រជុំនៅប្រទេសឥណ្ឌូណេស៊ី AIPA និង៤-បញ្ហាផ្សេងៗ។



❈នាថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣ នៅសាលប្រជុំគណៈកម្មការទី៦ព្រឹទ្ធសភា ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ដើម្បី៖

១-ពិនិត្យ និងពិភាក្សាអំពីទិសដៅការងារចុះសំណេះ-សំណាលក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ ក្នុងឆមាសទី២។

២-ពិនិត្យលើរបាយការណ៍សកម្មភាពការងារសម្រាប់នីតិកាលទី៤ របស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ (២០១៨-២០២៤)។



❈នាថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិនីតិ-កោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំការងារជាមួយនឹងឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា និងមន្ត្រីលេខាធិការដ្ឋាន ដើម្បីពិនិត្យការងាររៀបចំបោះពុម្ពសៀវភៅស្ដីពី វប្បធម៌ និងស្រាវជ្រាវឯកសារពាក់ព័ន្ធវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ដើម្បីត្រៀមចុះបំពេញបេសកកម្មទៅខេត្តក្រចេះ និងខេត្តត្បូងឃ្មុំ នៅសាលប្រជុំគណៈកម្មការទី៧ព្រឹទ្ធសភា។

❈ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញដឹកនាំប្រជុំផ្ទៃក្នុងគណៈកម្មការទី៧ព្រឹទ្ធសភា ដើម្បី៖

-ពិភាក្សាការងាររៀបចំចំណាប់អារម្មណ៍សម្រាប់ត្រៀមចុះបំពេញបេសកកម្មទៅខេត្តក្រចេះ និងខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣ នៅសាលប្រជុំគណៈកម្មការទី៧ព្រឹទ្ធសភា។



-ពិភាក្សា និងកែសម្រួលខ្លឹមសារឯកសារសម្រាប់ត្រៀម

ចុះបំពេញបេសកកម្មទៅខេត្តក្រចេះ និងខេត្តត្បូងឃ្មុំ នាថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ នៅសាលប្រជុំគណៈកម្មការទី៧ព្រឹទ្ធសភា។

❈លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំដូចខាងក្រោមៈ

-កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកាព្រឹទ្ធសភា ដើម្បីពិនិត្យ ពិភាក្សារបាយការណ៍បូកសរុបសកម្មភាពរបស់ក្រុមសមាជិកាព្រឹទ្ធសភា សម្រាប់នីតិកាលទី៤ព្រឹទ្ធសភា (២០១៨-២០២៤) និងបញ្ហាផ្សេងៗ នៅសាលប្រជុំគណៈកម្មការទី៨ព្រឹទ្ធសភា នាព្រឹកថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ នៅសាលប្រជុំគណៈកម្មការទី៨ព្រឹទ្ធសភា។



-កិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ ដើម្បីពិនិត្យ ពិភាក្សារបាយការណ៍បូកសរុបសកម្មភាពរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ សម្រាប់នីតិកាលទី៤ព្រឹទ្ធសភា (២០១៨-២០២៤) និងបញ្ហាផ្សេងៗ នាព្រឹកថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣ នៅសាលប្រជុំគណៈកម្មការទី៨ព្រឹទ្ធសភា។

-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៨ព្រឹទ្ធសភា នារសៀលថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣ ដើម្បីពិនិត្យ ពិភាក្សាលើៈ

១-របាយការណ៍បូកសរុបសកម្មភាពរបស់ក្រុមមិត្តភាពព្រឹទ្ធសភាជាមួយសភាសាធារណរដ្ឋសង្គមនិយមវៀតណាម សម្រាប់នីតិកាលទី៤ព្រឹទ្ធសភា (២០១៨-២០២៤)។

២-របាយការណ៍បូកសរុបសកម្មភាពរបស់ក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុកសហប្រតិបត្តិការជាមួយនឹងអន្តរសភាកម្ពុជា-ឡាវ-វៀតណាម (CLV) សម្រាប់នីតិកាលទី៤ព្រឹទ្ធសភា(២០១៨-២០២៤)។

និង៣-បញ្ហាផ្សេងៗ។



❈នាព្រឹកថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបាយការណ៍ថវិកា និងរបាយការណ៍ស្តីពី សកម្មភាពលទ្ធផលការងារប្រចាំខែសីហា និងលើកទិសដៅការងារបន្ត នៅសាលប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តម **ឆាយ ឫទ្ធិសែន** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំគណៈកម្មាធិការសមាជិកសភាអាយប៉ាវ័យក្មេង (YPA) ដើម្បីត្រៀមចូលរួមមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៤ (AIPA-44) នៅសាលប្រជុំពិសេស VIP3 ព្រឹទ្ធសភា៕

## ការទទួលពាក្យបណ្តឹង

❈នៅខែសីហា ឆ្នាំ២០២៣ គណៈកម្មការទី១ព្រឹទ្ធសភាបានទទួលពាក្យបណ្តឹងចំនួន២ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន២ករណី កំពុងពិនិត្យសិក្សាចំនួន២ករណី ឆ្លើយតបទៅម្ចាស់បណ្តឹង (ផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹង) ចំនួន៥ករណី ព្រមទាំងបានទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការចំនួន១ករណី៕

# សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨

❋នាព្រឹកថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តម **យ៉េង សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញនាំយកនូវទេយ្យវត្ថុ និងទៀនព្រះវស្សា ទៅប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សា នៅវត្តរកាកណ្តាល វត្តគោលាប់ និងវត្តបុសលាវ ព្រមទាំងនាំយកសៀវភៅទស្សនាវដ្តីព្រឹទ្ធសភា ទៅដាក់នៅក្នុងបណ្ណាល័យក្នុងក្រុងក្រចេះ ខេត្តក្រចេះ ។

❋ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងដឹកនាំក្រុមការងារបច្ចេកទេសចុះពិនិត្យដំណាំកសិកម្ម កសិឧស្សាហកម្ម និងហេដ្ឋារចនាសម្ព័ន្ធផ្លូវ លូ ស្ពាន និងទំនប់ទឹក នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យមើលមន្ទីរពេទ្យ ម៉ុង ឫទ្ធី សែនជ័យ និងហេដ្ឋារចនាសម្ព័ន្ធនានា នៅតំបន់អភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យស្ថានភាពទំនប់ទឹក និងពិនិត្យចម្ការដូងក្រអូប នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣។

-ទទួលជួបក្រុមវិនិយោគមកពីប្រទេសសិង្ហបុរីអញ្ជើញចុះមកទស្សនកិច្ច និងពិនិត្យសិក្សាឈ្វេងយល់អំពីវិស័យកសិកម្ម កសិ-ឧស្សាហកម្ម ប្រព័ន្ធធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធនានា នៅតំបន់អភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នារសៀលថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋបើកបររថយន្តដឹកពោត និងដំឡូងមី យកមកផ្គត់ផ្គង់ឱ្យរោងចក្រផលិតចំណីសត្វ ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួន នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នារសៀលថ្ងៃទី២ ខែសីហា ឆ្នាំ២០២៣។

-ទទួលជួបក្រុមវិនិយោគជនជាតិជប៉ុន ដែលមានបំណងចង់បង្កើតមជ្ឈមណ្ឌលមើលថែប្រជាពលរដ្ឋចាស់ជរានៅតំបន់អភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នៅការិយាល័យកណ្តាល ម៉ុង ឫទ្ធី រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ព្រមទាំងចុះពិនិត្យមើលទីតាំងគម្រោងសាងសង់សាលារៀនចំនួន១ខ្នង មាន៥បន្ទប់ ទីលានបាល់ទាត់ ទីលានបាល់បោះ និងចុះពិនិត្យមើលចម្ការដូងក្រអូប ទំនប់ទឹក និងហេដ្ឋរចនាសម្ព័ន្ធនានា នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នារសៀលថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល សួរសុខទុក្ខសិស្សានុសិស្ស និងចុះពិនិត្យដើមឈើដែលបានដាំនៅបរិវេណវត្តមហានាមស្លារម ឃុំរវៀង ព្រមទាំងសួរសុខទុក្ខប្រជាពលរដ្ឋអញ្ជើញមកសម្រាកកម្សាន្តនៅភ្នំតាម៉ៅ និងពិនិត្យមើលដើមឈើនៅបរិវេណភ្នំតាម៉ៅ ស្ថិតក្នុងស្រុកសំរោង ខេត្តតាកែវ នាព្រឹកថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល សួរសុខទុក្ខប្រជាពលរដ្ឋ និងចុះណែនាំពួកគាត់អំពីការថែទាំដី ដើម្បីដាំដំណាំស្រូវទទួលបានផលល្អ ព្រមទាំងសួរសុខទុក្ខប្រជាពលរដ្ឋអញ្ជើញមកសម្រាកកម្សាន្ត និងទស្សនាសួនសត្វ ព្រះវិហារ និងសហចេតិយ នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣ ។

-ទទួលព្រះសង្ឃចំនួន១០០អង្គ និមន្តមកពីវត្តមហានាមស្លារម តាជី យាយជី សិស្សានុសិស្ស ប្រជាជនក្រីក្រអញ្ជើញមកទស្សនកិច្ចនៅតំបន់អភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ និងបានប្រគេនចង្ហាន់ពេលព្រឹក និងអាហារថ្ងៃត្រង់ និងបច្ច័យមួយចំនួនដល់ព្រះសង្ឃ និងប្រជាពលរដ្ឋ ព្រមទាំងជួបសំណេះសំណាលកម្មករ និងដឹកនាំក្រុមអ្នកជំនាញកសិកម្ម ចូលរួមដាំកូនឈើអូញម៉ូញត្របែកព្រៃ និងសាគូវ៉ា ដើម្បីចូលរួមថែរក្សាការពារព្រៃឈើ

និងបរិស្ថានជាមួយរាជរដ្ឋាភិបាល នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះដឹកនាំក្រុមការងារបច្ចេកទេសសំណង់សាងសង់ហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ ទឹក ភ្លើង នៅលើផ្ទៃដី១៧២ហិកតា ដើម្បីត្រៀមបម្រើសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នារសៀលថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣។

-ទទួលជួបលោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស អញ្ជើញមកពីវិទ្យាស្ថានកសិកម្ម ម៉ុង ឫទ្ធី កែវផុស OMRA ចំនួន១២០នាក់ មកបំពេញទស្សនកិច្ចសិក្សាឈ្វេងយល់វិស័យកសិកម្ម កសិ-ឧហ្សាហកម្ម នៅតំបន់អភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋអញ្ជើញមកសម្រាកកម្សាន្ត និងទស្សនាតំបន់កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នារសៀលថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋអញ្ជើញមកសម្រាកកម្សាន្ត និងទស្សនាតំបន់កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ ព្រមទាំងជួបសំណេះសំណាលសួរសុខទុក្ខកម្មករ និងពិនិត្យមើលទំនប់ទឹក និងហេដ្ឋារចនាសម្ព័ន្ធនានា នៅភ្នំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៣។

❈នាថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៣ ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផល នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅខេត្តព្រៃវែង ។

❈លោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី ម៉ូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់មហាកុដិដាក់



ទៀនចំណាំព្រះវស្សា ព្រមទាំងជួបសំណេះសំណាលតាជី យាយជី នៅវត្តសន្លុង ឃុំសន្លុង ស្រុកទ្រាំង ខេត្តតាកែវ នាថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣។



-ជួបសំណេះសំណាលប្រជាពលរដ្ឋ និងឧបត្ថម្ភក្រមា១ សារុង១ ថវិកាមួយចំនួនដល់ស្ត្រី៧នាក់ ព្រមទាំងចុះសួរសុខទុក្ខគ្រួសារសពលោក **ឃុត ឃឹន** អតីតសមាជិកក្រុមប្រឹក្សាឃុំជ្រៃលាស់ និងអតីតប្រធានភូមិទួលព្រិច ដែលបានទទួលមរណភាពដោយរោគាពាធ និងចូលរួមបច្ច័យបុណ្យមួយចំនួន នៅឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្ដាល នាថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៣។



-ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នៃមូលនិធិប៉ាយសួយឡាវយ៉ិនកម្ពុជាចំនួន១៥០នាក់ ដឹកនាំដោយលោកព្រឹទ្ធាចារ្យវេជ្ជបណ្ឌិត **វ៉ាង ស៊ិនមិង** ពិនិត្យព្យាបាលជូនប្រជា-

ពលរដ្ឋ នៅស្រុកពញាឮចំនួន១.៥០០នាក់។ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន ទឹកស៊ីអ៊ីវចំនួន១.៥០០ដប និងអង្ករ១៥.០០០គីឡូក្រាម ជូនប្រជាពលរដ្ឋ នៅសាលាបឋមសិក្សាភ្នំអង្គរវស្ស ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្ដាល នាថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៣។

❈នាថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៣ ឯកឧត្ដម **អ៊ុក ម៉ុនឈឿន** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមជួបសំណេះសំណាលប្រជាពលរដ្ឋ ដើម្បីផ្សព្វផ្សាយអំពីលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ នៅភូមិពពេល ឃុំពពេល ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។



❈នាថ្ងៃទី១៤ និងថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ឯកឧត្ដមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាសង្កាត់ស្ទោរ សង្កាត់ឪឡោក ខណ្ឌកំបូល រាជធានីភ្នំពេញ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន។

❈លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលប្រជាពលរដ្ឋ នៅភូមិព្រៃទឹង និងភូមិពោធិ៍ទី ឃុំព្រៃទឹង ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង នាព្រឹកថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលប្រជាពលរដ្ឋ នៅអំពិលក្រៅ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង នាព្រឹកថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៣។

❈ឯកឧត្ដម **ខៀវ មុត** អនុប្រធានគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ នៅឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ នាព្រឹកថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៣។

-ចូលរួមសំណេះសំណាលក្រុមប្រឹក្សាឃុំ នៅឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ នាព្រឹកថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣។

❈ឯកឧត្ដម **ចាន់ ណារ៉េត** អនុប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា និងឯកឧត្ដម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការ នៃមជ្ឈមណ្ឌលបន្សាបព្យាបាល និងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀនខេត្តបាត់ដំបង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅភូមិស្ដៅ ឃុំស្ដៅ ស្រុករតនមណ្ឌល ខេត្តបាត់ដំបង នាព្រឹកថ្ងៃទី២ ខែសីហា ឆ្នាំ២០២៣។



-ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសាលាបឋមសិក្សាបាយដំរាំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលាបឋមសិក្សាបាយដំរាំ ភូមិតាស៊ង ឃុំបាយដំរាំ ស្រុកបាណន់ ខេត្តបាត់ដំបង នារសៀលថ្ងៃទី២ ខែសីហា ឆ្នាំ២០២៣។

❈នាថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣ ឯកឧត្ដម **ម៉ុល លីម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា ឯកឧត្ដម **ណាំ ទុំ** លេខាធិការគណៈកម្មការទី១ព្រឹទ្ធសភា និងឯកឧត្ដម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផល នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចក្រឡាហោម

**ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលសុភមង្គល ក្រុងបាត់ដំបង ខេត្តបាត់ដំបង។

❈នាថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៣ ឯកឧត្តម **អោយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមជួបសំណេះសំណាលប្រជាពលរដ្ឋ ដើម្បីផ្សព្វផ្សាយអំពីលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ នៅខេត្តកោះកុង។

❈ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមប្រជុំជាមួយមេភូមិទាំង១៣ និងក្រុមប្រឹក្សាសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីផ្សព្វផ្សាយប្រតិទិនការងាររបស់គណៈកម្មការជាតិរៀបចំការបោះឆ្នោត នាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣។



-ជួបសំណេះសំណាលនិងឧបត្ថម្ភកង់ចំនួន១០គ្រឿង ដល់មន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅមុខអគារ E វិមានព្រឹទ្ធសភា នាថ្ងៃទី២ ខែសីហា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលសមាគមមនុស្សចាស់ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីពិនិត្យលទ្ធភាពអំពីសំណូមពរចំពោះមុខលើការងារថែទាំសុខភាពជនចាស់ជរា និងរៀបចំកម្មវិធីចុះជាក់ស្ដែងតាមខ្នងផ្ទះឱ្យ



បានទាន់ពេលវេលា ព្រមទាំងឧបត្ថម្ភអង្ករ សម្ភារប្រើប្រាស់ និងថវិកាមួយចំនួន នាថ្ងៃទី៣ និងថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣។



-ចូលរួមជាមួយលោកប្រធានក្រុមប្រឹក្សាសង្កាត់ទឹកល្អក់ទី២ លោកប្រធានភូមិទី៣ ពិនិត្យការដ្ឋានពង្រីកប្រព័ន្ធលូសាធារណៈជូនបងប្អូនប្រជាពលរដ្ឋប្រវែង២៥០ម៉ែត្រ នៅផ្លូវលេខ១៥០ ភូមិទី៣ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ នាថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៣។



-ចូលរួមពិធីបិទវគ្គបណ្ដុះបណ្ដាលស្ដីពី ការតម្រង់ទិសដល់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត និងការផ្ទេរមុខការទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រោមអធិបតីភាពឯកឧត្តម **ម៉ប់ សារិន** ប្រធានសមាគមជាតិក្រុមប្រឹក្សារាជធានីខេត្ត នៅរាជធានីភ្នំពេញ នាថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៣។



-នាំយកនូវទេយ្យទាន គ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួន ទៅថ្វាយសម្ដេចព្រះសង្ឃនាយករងទី២ **ណយ ច្រឹក** ព្រះចៅអធិការវត្ត និងព្រះសង្ឃគង់ចាំព្រះវស្សាអស់កាលត្រីមាស នៅវត្តចន្ទបុរីវង្ស ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ នាថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣។

❋ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនិស្សិតមហាវិទ្យាល័យកសិកម្ម នៃសាកលវិទ្យាល័យស្វាយរៀង នៅខេត្តស្វាយរៀង នាថ្ងៃទី២១ និងថ្ងៃ២៨ ខែកក្កដា និងថ្ងៃទី៤ និងថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋគ្រប់ភូមិ ក្នុងឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី៦ និងថ្ងៃទី៩ ដល់ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣។

-ចូលរួមជាអធិបតីភាពក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារ និងលើកទិសដៅការងារបន្តរបស់រដ្ឋបាលខេត្តស្វាយរៀង នៅសាលប្រជុំខេត្តស្វាយរៀង នាថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៣។

-ចូលរួមជាអធិបតីភាពក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារ និងលើកទិសដៅការងារបន្តរបស់រដ្ឋបាលស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៣។

❋ឯកឧត្តម **ហែម ខន** អនុប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារសពលោក **អេ តាំង** អតីតមន្ត្រីមន្ទីរសុខាភិបាលខេត្តកំពង់ស្ពឺ ព្រមទាំងចូលបច្ច័យបុណ្យមួយចំនួន នៅសង្កាត់សុព័រទេព ក្រុងច្បារមន ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២ ខែសីហា ឆ្នាំ២០២៣។

-ចូលរួមរំលែកទុក្ខក្រុមគ្រួសារសពលោក **ជៀប សារី** សមាជិកក្រុមប្រឹក្សាសង្កាត់ស្វាយក្រវ៉ាន់ ព្រមទាំងចូលបច្ច័យបុណ្យមួយចំនួន នៅសង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣។

-ចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារសពលោក **ជួន សយ** សមាជិកក្រុមប្រឹក្សាឃុំព្រៃវិហារ ព្រមទាំងចូលបច្ច័យបុណ្យមួយចំនួន នៅឃុំព្រៃវិហារ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣។

-ជាកិត្តិយសក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ក្រោមអធិបតីភាពឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ឆាយ ថន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ នៅក្រុងច្បារមន ខេត្តកំពង់ស្ពឺ នារសៀលថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣។

❋ឯកឧត្តម **ណៅ ទុំ** លេខាធិការគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋនៅឃុំសំឡូត និងឃុំតាតោក ស្ថិតក្នុងស្រុកសំឡូត ខេត្តបាត់ដំបង នាថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការវិមានឯករាជ្យ សួនធ្នង់៥៣ និងផ្លូវចាក់កៅស៊ូបេទីម ក្រោមអធិបតីភាពសម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅបរិវេណវិមានឯករាជ្យ ក្រុងបាត់ដំបង ខេត្តបាត់ដំបង នាព្រឹកថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣។

❋នាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តម **អន ស៊ុំ** លេខាធិការគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីឈ្វេងយល់ពីការងារផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋ បញ្ហាប្រឈម និងសំណូមពរនានា នៅខេត្តបន្ទាយមានជ័យ។

❋ឯកឧត្តម **ឆាយ ឫណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភា និងឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញចូលរួមប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកក្កដា និងលើកទិសដៅការងារបន្តសម្រាប់ខែខាងមុខ ឆ្នាំ២០២៣ របស់រដ្ឋបាលស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ក្រោមអធិបតីភាពឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅសាលាស្រុកត្បូងឃ្មុំ ខេត្ត



ត្បូងឃ្មុំ នាថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៣។



❋នាថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៣ ឯកឧត្តម **ឆាយ ឫទ្ធិសែន** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញនាំយកអំណោយអំពូលសូឡាទៅចែកជូនបងប្អូនប្រជាពលរដ្ឋខ្មែរឥស្លាម សម្រាប់ដាក់បំភ្លឺ នៅតាមវិហារឥស្លាម នៅឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ។

❋ឯកឧត្តម **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីប្រគេនទៀនវស្សា និងសម្ភារៈបរិក្ខារចំនួនប្រាំវត្ត ព្រមទាំងចែកកន្សែង និងថវិកាមួយចំនួនដល់អ្នកចូលរួមផងដែរ នៅក្នុងវត្តបាក្រុង ឃុំស្វាយចេក ស្រុករំដួល ខេត្តស្វាយរៀង នាថ្ងៃទី២ ខែសីហា ឆ្នាំ២០២៣។

-ចូលរួមជាកិត្តិយសជាមួយសមាគមសប្បុរសធម៌ ប៉ាវ សួយ ឡាវ យិន កម្ពុជា និងវេជ្ជបណ្ឌិតពិនិត្យព្យាបាលជំងឺជូនប្រជាជនក្នុងឃុំចំនួន៣គឺ៖ ឃុំពោធិ៍រាជ ឃុំតាសួស ឃុំស្វាយជ្រំ ក្រៅពីថ្នាំពេទ្យក្រុមគ្រូពេទ្យក៏បានឧបត្ថម្ភសម្ភារៈមួយចំនួនជូនអ្នកជំងឺថែមទៀតផង នៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង នាថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣។

-ចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផល នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ ក្រោមអធិបតីភាពសម្ដេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច នៅសាលាខេត្តស្វាយរៀង នាថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៣។

-រៀបចំបុណ្យទក្ខិណានុប្បទានជូនឧបាសិកា **ញ៉ឹក គឹមលាង** និងឧបាសក **គឹម ត្នួន** ដែលមរណភាពអស់ ២៣ឆ្នាំ និង៨ឆ្នាំ ព្រមទាំងសាច់ញាតកា៧សន្ដាន បានចែកឋានកន្លងមក នៅក្រុងស្វាយរៀង ខេត្តស្វាយរៀង នាថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៣។

❋ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយបងប្អូនប្រជាពលរដ្ឋចំនួន ១០ភូមិ នៅឃុំទ្រាស់ និងឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី២៦ ដល់ថ្ងៃទី៣១ ខែកក្កដា និងថ្ងៃទី១ ថ្ងៃទី២ ខែសីហា ឆ្នាំ២០២៣។



-នាំយកកូនដើមឈើចំនួន១.០៣០ដើម ប្រភេទកូនដើមឈើកកោះ កូនដើមឈើគ្រញូង កូនដើមឈើធ្នុង កូនដើមឈើចា កូនដើមឈើបេង និងកូនដើមឈើក្ដុលមាស ពីនាយករដ្ឋបាលសង្កាត់ព្រៃឈើថ្មពួក សម្រាប់ចែកជូននាយកសាលាទាំងអស់ ក្នុងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២២។

❋លោកជំទាវ **មុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមគោរពវិញ្ញាណក្ខន្ធសពលោកស្រី **ម៉ុត ធីតា** អតីតចៅសង្កាត់ផ្សារថ្មីទី៣ នៅខណ្ឌដូនពេញ រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ នៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី២ ខែសីហា ឆ្នាំ២០២៣។

❋ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាអធិបតីភាពក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រនីតិកាលទី៧ ឆ្នាំ២០២៣ និងបានរៀបចំពិធីពិសាអាហារសាមគ្គីជូនក្រុមការងារ និងអាជ្ញាធរមូលដ្ឋាន នៅស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋស្រុកអូររាំងឪ នៅវិទ្យាល័យ ហ៊ុន សែន អូររាំងឪ ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៣។

-ជាអធិបតីភាពក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ដ្រនីតិកាលទី៧ ឆ្នាំ២០២៣ ជាមួយក្រុមការងារចុះជួយស្រុកអូររាំងឪ នៅស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៣។

❋នាថ្ងៃទី១៤ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ឯកឧត្តម **ថុង ចន់** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ នៅស្រុកមណ្ឌលសីមា ខេត្តកោះកុង។



❋ឯកឧត្តម **ខឹម លាង** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា និងលោកជំទាវ **ស៊ី វណ្ណថា** សមាជិកាគណៈ-កម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញជួបពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំ ប្រធានភូមិ នាយប៉ុស្តិ៍នគបាលឃុំ នាយកសាលា ដើម្បីឈ្វេងយល់ការអនុវត្ត និងដកបទពិសោធន៍ការងារកន្លងទៅ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនដល់គ្រួសារសពចំនួន៦គ្រួសារ និងស្ត្រីសម្រាលកូនចំនួន១១នាក់ និងជូនសមាជិកអង្គប្រជុំចំនួន១៩នាក់ នៅឃុំត្រពាំងគរ ស្រុកជើងព្រៃ ខេត្តកំពង់ចាម នាថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣។

❋នាថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣ ឯកឧត្តម **ខឹម លាង** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាអធិបតីភាពក្នុងកិច្ចប្រជុំបូកសរុបការងារ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ម៉ា ឈឿន** ប្រធានក្រុមការងារថ្នាក់កណ្ដាលចុះជួយស្រុកជើងព្រៃ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនជូនសមាជិកអង្គប្រជុំ និងនៅចុងបញ្ចប់ នៃកម្មវិធីបានពិសាអាហារសាមគ្គី១ពេលរួមគ្នា នៅស្រុកជើងព្រៃ ខេត្តកំពង់ចាម។

❋ឯកឧត្តម **ញ៉ែប សុខ** សមាជិកគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ៖

-នាំយកទៀនព្រះវស្សា ថវិកាបច្ច័យបួន ថវិកាកសាងវត្ត និងបរិក្ខារដូចជា សាដក អំពូលសូឡា ព្រមទាំងទេយ្យវត្ថុ ដូចជា៖ អង្ករ មី ទឹកត្រី ទឹកស៊ីអ៊ីវ ត្រីខ ទឹកក្រូច ទឹកបរិសុទ្ធ ដើម្បីប្រគេនព្រះសង្ឃចំនួន២វត្តគឺ៖ វត្តសង្រ្កែ ក្នុងឃុំសង្រ្កែ និងវត្តភ្នំប្រោសសត្វ ក្នុងស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ដើម្បីព្រះសង្ឃប្រើប្រាស់ក្នុងឱកាសគង់ចាំព្រះវស្សាអស់មួយត្រីមាស នាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣។

-នាំយកថវិកាបច្ច័យបួន ព្រមទាំងគ្រឿងឧបភោគ បរិភោគ រួមមាន៖ អង្ករ ត្រីខ មី ទឹកត្រី ទឹកស៊ីអ៊ីវ ទឹកក្រូច ទឹកបរិសុទ្ធ ទៅប្រគេនព្រះសង្ឃក្នុងវត្តពោធិ៍សុវណ្ណរង្សី ក្នុងឃុំអន្លង់វិល ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់ ក្នុងឱកាសបុណ្យចូលព្រះវស្សា នាថ្ងៃទី១ ខែសីហាឆ្នាំ ២០២៣។

❋ឯកឧត្តម **ច្រឹង គឹមស្រ៊ាន** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមពិធីគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ និងបានឧបត្ថម្ភថវិកាមួយចំនួនដល់គ្រួសារសព នៅស្រុកស្ទឹង-ត្រង់ ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី២ ខែសីហា ឆ្នាំ២០២៣។

-នាំយកទៀនព្រះវស្សា និងគ្រឿងទេសមួយចំនួនប្រគេនព្រះសង្ឃគង់ចាំព្រះវស្សា រួមមាន៖ ទៀនចំនួន១គូ អង្ករចំនួន១បេ ទឹកបរិសុទ្ធ២កេស ទឹកក្រូច២កេស មី២កេស ត្រីខ១យួរ ទឹកត្រី១យួរ ទឹកស៊ីអ៊ីវ១យួរ ទឹកដោះគោខាប់៥កំប៉ុង ស្ករ-ស២គីឡូក្រាម និងបច្ច័យប្រគេនព្រះសង្ឃមួយចំនួន ព្រមទាំងជូនថវិកាមួយចំនួនដល់តាជីយាយជី និងប្រជាការពារចំនួន២៥នាក់ នៅវត្តសុវណ្ណគង្គារ ហៅវត្តបឹងកេត ឃុំព្រែកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខក្រុមប្រឹក្សាឃុំ ប្រធានភូមិ នគរបាលប៉ុស្តិ៍រដ្ឋបាល និងចុះពិនិត្យគម្រោងមូលនិធិផ្លូវបេតុងប្រវែង៥២០ម៉ែត្រ ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួនដល់ឃុំផងដែរ នៅឃុំព្រះអណ្ដូង ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៣។

❈ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅភូមិកំពង់សំរោង ឃុំកំពង់សំរោង ស្រុកទឹកឈូ ខេត្តកំពត នារសៀលថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនដល់ប្រធានភូមិ នៅភូមិកំពង់កែស ឃុំត្រពាំងសង្កែ ខេត្តកំពត នាថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ នៅភូមិបឹងតារោង ឃុំព្រៃឃ្មុំ ខេត្តកំពត នារសៀលថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋកំពុងសម្រាកព្យាបាលជំងឺ ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួនដល់អ្នកជំងឺ នៅមន្ទីរពេទ្យកំពតស្ដង់ដា ភូមិបឹងតារោង ឃុំព្រៃឃ្មុំ ស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣។

❈នាថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣ ឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋ នៅឃុំក្លាំងហាយ ស្រុកស្រីស្នំ ខេត្តសៀមរាប។

❈លោកជំទាវ **ឃួន យុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាអធិបតីភាពក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកក្កដា ឆ្នាំ២០២៣ ព្រមទាំងឧបត្ថម្ភដល់សាលាឃុំទាំង ១១ ក្នុងស្រុកកំពង់ស្វាយ ដោយក្នុង១ឃុំទទួលបានថវិកាមួយចំនួន និងស្រាបៀរអង្គរចំនួន១០កេស ដើម្បីរៀបចំអាហារសាមគ្គីតាមបណ្ដាឃុំរៀងៗខ្លួន ចំណែកឃុំធំៗចំនួន ១៥កេស ដោយឡែកប្រធានគណៈកម្មាធិការស្រុកឧបត្ថម្ភថវិកាមួយចំនួន និងស្រាបៀរ២០កេស នៅសាលាស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ខេត្តកំពង់ធំ នាថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣។



-នាំយកទៀនចំណាំព្រះវស្សា ទេយ្យទាន សម្ភារៈបរិក្ខារ និងថវិកាមួយចំនួនវេរប្រគេនព្រះគ្រូចៅអធិការវត្តចំនួន៨វត្តក្នុងស្រុកកំពង់ស្វាយ ព្រមទាំងជួបសំណេះសំណាលលោកយាយ លោកតា មា មីង បងប្អូន នៅវត្តក្តីចាវ៍ ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៣។



-ជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋដែលអញ្ជើញមកទទួលសេវាពិនិត្យ និងព្យាបាលជំងឺដោយឥតគិតថ្លៃពីសំណាក់ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នៃសាធារណរដ្ឋកូរ៉េ ដឹកនាំដោយឯកឧត្តម **សួស យ៉ារ៉ា** អ្នកតំណាងរាស្ត្រមណ្ឌលខេត្តកំពង់ធំ ដែលមានប្រជាពលរដ្ឋអញ្ជើញមកទទួលពិនិត្យ និងព្យាបាលជំងឺសរុបចំនួន៣.៦១០នាក់ នៅមន្ទីរពេទ្យខេត្តកំពង់ធំ នាព្រឹកថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣។

-រៀបចំពិធីអាហារសាមគ្គីជូនក្រុមគ្រូពេទ្យស្ម័គ្រចិត្តខេត្តយ្យុងសាងប៊ុកដូ នៃសាធារណរដ្ឋកូរ៉េ និងក្រុមយុវជនស្ម័គ្រចិត្ត ដើម្បីរីតចំណងសាមគ្គីភាព បង្កើនភាពស្និទស្នាល ព្រមទាំងជូនលិខិតថ្លែងអំណរគុណដល់ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត និងក្រុមយុវជនស្ម័គ្រចិត្ត នៅភោជនីយដ្ឋាន ឡូវ




គីមសេង ក្រុងស្ទឹងសែន ខេត្តកំពង់ធំ នារសៀលថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣។

-ចូលរួមជាគណៈអធិបតីភាពក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការអនុវត្តផែនការសកម្មភាពឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ជា ចាន់តូ** ដែលមានសមាជិកចូលរួមសរុបចំនួន១.៧៩៨នាក់ នៅភោជនីយដ្ឋានឡូវ គីមសេង ក្រុងស្ទឹងសែន ខេត្តកំពង់ធំ នាថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៣។

❈នាថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៣ ឯកឧត្តម **ស្រី បេន** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋចំនួន៣៥០នាក់ ក្នុងភូមិវែង ឃុំសឹង្ហ ដើម្បីផ្សព្វផ្សាយអំពីលទ្ធផល នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនជូនអ្នកចូលរួម នៅភូមិវែង ឃុំសឹង្ហ ស្រុកសំរោង ខេត្តតាកែវ។

❈ឯកឧត្តម **ឡៅ ឆន** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមបុណ្យផ្កាប្រាក់ និងនាំយកទៀនព្រះវស្សា ព្រមទាំងទេយ្យវត្ថុ បច្ច័យមួយចំនួនប្រគេនព្រះសង្ឃ នៅវត្តនគរភាស ឃុំនគរភាស ស្រុកអង្គរជុំ ខេត្តសៀមរាប នាថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៣។

-ចូលរួមប្រជុំជាមួយក្រុមប្រឹក្សាឃុំទាំង៦ ដើម្បីដកស្រង់បទពិសោធន៍ការងាររៀបចំបោះឆ្នោតជ្រើសតាំងតំណាង-រាស្ត្រនីតិកាលទី៧ ក្រោមអធិបតីភាពឯកឧត្តមកិត្តិសង្គហបណ្ឌិត **គន់ គីម** ទេសរដ្ឋមន្ត្រី នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ នាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣។



-នាំយកនូវទេយ្យទាន គ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួន ទៅប្រគេនព្រះសង្ឃគង់ចាំព្រះវស្សាអស់កាលត្រីមាស ដើម្បីទុកសម្រាប់ព្រះសង្ឃរៀបចំចង្ហាន់ក្នុងរដូវចូលព្រះវស្សា តាមប្រពៃណីព្រះពុទ្ធសាសនា នៅវត្តឥន្ទ្រាសុខារាម ហៅវត្តគោកប៉ាទ្រី នៅសង្កាត់សៀមរាប និងវត្តព្រះព្រហ្មរតន៍ នៅសង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប នាថ្ងៃទី២ និងថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៣។



-ចុះសួរសុខទុក្ខលោក **ហុង ឧប្បលវណ្ណា** អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តសៀមរាប មានជំងឺជាទម្ងន់ដែលកំពុងសម្រាកព្យាបាលជំងឺ នៅមន្ទីរពេទ្យកាល់ម៉ែត្ររាជធានីភ្នំពេញ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នាថ្ងៃទី ១១ ខែសីហា ឆ្នាំ២០២៣។

❈ឯកឧត្តម **អ៊ឹង លាងហ៊្វី** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ ដើម្បីផ្សព្វផ្សាយរបាយការណ៍បឋមស្តីពីលទ្ធផល នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** នៅខេត្តកំពង់ឆ្នាំង នាថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣។

-នាំយកនូវគ្រឿងឧបភោគ បរិភោគ បច្ច័យ៤ និងថវិកាសម្រាប់ចំណាយថ្លៃអគ្គិសនីបំភ្លឺវត្ត ទៅប្រគេនព្រះសង្ឃគង់ចាំព្រះវស្សាអស់កាលត្រីមាស ដើម្បីទុកសម្រាប់ព្រះសង្ឃរៀបចំចង្ហាន់ក្នុងរដូវចូលព្រះវស្សា តាមប្រពៃណីព្រះពុទ្ធសាសនា ស្ថិតនៅវត្តធម្មវន្ត ឃុំក្រាំងដីមាស ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង នាថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៣។

-ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំទាំង៥ ដើម្បីពិនិត្យចងក្រងឯកសាររដ្ឋបាលឃុំ ស្រុក និងកែសម្រួលរបាយការណ៍បូកសរុបលទ្ធផលការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ តាមការិយាល័យបោះឆ្នោតនីមួយៗ នៅស្រុកជលគីរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី៧ និងថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៣។

-នាំយកនូវគ្រឿងឧបភោគ បរិភោគ បច្ច័យ៤ និងថវិកាសម្រាប់ចំណាយថ្លៃអគ្គិសនីបំភ្លឺវត្ត ទៅប្រគេនព្រះសង្ឃគង់ចាំព្រះវស្សាអស់កាលត្រីមាស នៅវត្តពោធិ៍សត្ថារាម ឃុំកំពង់ហៅ ស្រុកកំពង់លែង វត្តព្រះធាតុឆ្វេង និងវត្តបល្ល័ង្គ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង នាថ្ងៃទី១៥ និងថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣។

❋ឯកឧត្តម **សាយ ម៉ូរិន** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាអធិបតីភាពក្នុងការប្រជុំបូកសរុបលទ្ធផលការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាថ្ងៃទី២៧ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣។

-ចូលរួមអមដំណើរសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា អញ្ជើញប្រគេនទៀនព្រះវស្សាដល់វត្តទាំងអស់ក្នុងស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ វត្តទាំងអស់ក្នុងស្រុករមាសហែក ខេត្តស្វាយរៀង និងវត្តទាំងអស់ក្នុងស្រុកកំចាយមារ ខេត្តព្រៃវែង ដែលប្រារព្ធរួមនៅក្នុងវត្តថ្កូវភូមិអន្លង់ជ្រៃ ឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលប្រជាពលរដ្ឋ និងប្រគល់ប័ណ្ណសរសើរជូនដល់ថ្នាក់ដឹកនាំភូមិទាំង២១ ក្នុងឃុំដូនតី ឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៣។

-ចូលរួមប្រជុំបូកសរុបលទ្ធផលការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ នៅស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នាថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៣។

❋នាព្រឹកថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣ លោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញនាំយកអង្ករ ទេយ្យទាន និងបច្ច័យមួយចំនួនទៅវេរប្រគេនព្រះសង្ឃគង់នៅវត្តព្រះឥន្ទកោសា វត្តព្រះឥន្ទកោសីយ៍ និងវត្តអង្គរខាងជើង នៅក្រុងសៀមរាប ខេត្តសៀមរាប។

## សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស



❋នាថ្ងៃទី២១ ដល់ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣ ឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញចូលរួមកិច្ចប្រជុំ នៃវេទិកាសមាជិកសភាអាស៊ីប៉ាស៊ីហ្វិកលើកទី៧ ស្តីពី “សុខភាពសកល” (APPFGH-7) នៅទីក្រុងអ៊ូឡង់បាទ័រ ប្រទេសម៉ុងហ្គោលី។

# សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ



❈នាយប់ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ សមាជិក សមាជិកាព្រឹទ្ធសភា ចំនួន៦រូប បានអញ្ជើញចូលរួមអបអរសាទរទិវាបុណ្យឯករាជ្យជាតិលើកទី៧៧ នៃសាធារណរដ្ឋឥណ្ឌា រៀបចំដោយលោកជំទាវបណ្ឌិត Devyani Khobragade ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋឥណ្ឌា ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងលោកបណ្ឌិត Aakash Singh នៅសណ្ឋាគារ Hyatt Regency Phnom Penh។



❈នាថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ខា ខេង្គ** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធឧបាសិកា **គ្រុយ ឆេង** ត្រូវជាម្ដាយមីងបង្កើត ដែលបានទទួលមរណភាពក្នុងជន្មាយុ៩៧ឆ្នាំ ដោយជរាពាធ នៅភូមិស្រង៉ែ ឃុំស្រង៉ែ ស្រុកព្រៃឈរ ខេត្តកំពង់ចាម។

❈នាថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣ ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា និងឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរបុណ្យជាតិខួបលើកទី៥៨ របស់ប្រទេសសិង្ហបុរី ដែលរៀបចំឡើងដោយឯកឧត្តម Two Lay Cheng ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃប្រទេសសិង្ហបុរី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសូហ្វីតែល-ភូគីត្រា រាជធានីភ្នំពេញ។






❈នាព្រឹកថ្ងៃទី៣ ខែសីហា ឆ្នាំ២០២៣ លោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី ម៉ូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា ឯកឧត្តម **គង់ សារាជ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា និងឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីសម្ពោធបើកឱ្យប្រើប្រាស់ជាផ្លូវការផ្លូវក្រវាត់ក្រុងទី៣ និងផ្លូវខ្នែងប្រវែង៥២,៩៨៣គីឡូម៉ែត្រ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្ដាល។

❈នាល្ងាចថ្ងៃទី១ ខែសីហា ឆ្នាំ២០២៣ លោកជំទាវ **មុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីជួបជុំពិសាអាហារសាមគ្គីជាមួយឯកឧត្តមបណ្ឌិត **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ នៅភោជនីយដ្ឋានឡេវទីហ្វាង៕

# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកក្កដា និងទិសដៅការងារខែសីហា ឆ្នាំ២០២៣




*ឯកឧត្តម ឡោក ឆាយ ឯកឧត្តម អ៊ុំសារឹទ្ធ ឯកឧត្តម លឹម ប៊ុនហុក*

នាព្រឹកថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែកក្កដា និងលើកទិសដៅការងារសម្រាប់ខែសីហា ឆ្នាំ២០២៣ នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចាប់ពីអនុប្រធាននាយកដ្ឋានឡើង។

មានប្រសាសន៍ក្នុងឱកាសនោះ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងខែកក្កដាថា មន្ត្រីរាជការ និងប្រជាពលរដ្ឋកម្ពុជាទូទាំងប្រទេសយ៉ាងច្រើនកុះករបានទៅបោះឆ្នោតសកល នាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ដើម្បីអនុវត្តសិទ្ធិក្នុងការជ្រើសរើសតំណាងរបស់ខ្លួនតាមបែបប្រជាធិបតេយ្យ ដែលបានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ក្នុងបរិយាកាសអព្យាក្រឹត សន្តិភាព របៀបរៀបរយ គ្មានអំពើហិង្សា និងគ្មានការគំរាមកំហែង។ ក្នុងបរិបទនេះ ព្រឹទ្ធសភាដើរតួនាទីស្នូលក្នុងការបំពេញមុខងារសហប្រតិបត្តិការអន្តរជាតិជំនួសរដ្ឋសភា ដែលតម្រូវឱ្យអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបង្កើនការយកចិត្តទុកដាក់ខ្ពស់លើកិច្ចការទូតសភាក្នុងកម្រិតតំបន់ និងអន្តរជាតិ។

សម្រាប់ខែសីហាខាងមុខ ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានណែនាំដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវត្រៀមសព្វសារពើសម្រាប់ការងារខាងមុខ គឺជារឿងអាទិភាពដែលគ្រប់ថ្នាក់ គ្រប់ផ្នែក គ្រប់វិស័យ ត្រូវតែខិតខំជាអតិបរមា ដើម្បីឆ្ពោះទៅរកការរៀបចំលក្ខណសម្បត្តិសព្វយ៉ាងទាំងទីកន្លែងធ្វើការ ធនធានសម្ភារ បរិក្ខារ បច្ចេកទេស បច្ចេកវិទ្យា និងហិរញ្ញវត្ថុមានគ្រប់គ្រាន់ក្នុងដៃ និងម្ចាស់ការលើការរៀបចំឱ្យបានទាន់ពេលវេលាដូចការគ្រោងទុក ពីព្រោះពេលវេលាកាន់តែលឿនទៅមុខ ដើម្បីសម្រេចផែនការយុទ្ធសាស្ត្រព្រឹទ្ធសភាឌីជីថល និងបៃតង ២០២៤-២០៣០ ក្នុងបរិបទ នៃព្រឹទ្ធសភានីតិកាលទី៥។ ការវិនិយោគបន្ថែមថ្មីៗ ដើម្បីបំពេញតម្រូវការមូលដ្ឋានសម្ភារបច្ចេកទេស បច្ចេកវិទ្យា បរិស្ថាន និងទីកន្លែងធ្វើការសម្រាប់នីតិកាលថ្មី គឺជាកិច្ចការពិសេសបន្ទាន់ និងចាំបាច់បំផុត។ ជាមួយគ្នានេះ ថ្នាក់ដឹកនាំ មន្ត្រីរាជការទាំងអស់ត្រូវបន្តយកចិត្តទុកដាក់ផ្តល់សេវាជូនសមាជិក សមាជិកាព្រឹទ្ធសភា លើមុខងារទាំង៥របស់ព្រឹទ្ធសភាឱ្យគ្រប់ជ្រុងជ្រោយ ប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល កាន់តែល្អប្រសើរឡើងបន្ថែមទៀត។

(អត្ថបទ៖ វង់ សុជាតិ រូបភាព៖ គង់ យ៉ារីន)



*ទិដ្ឋភាពក្នុងកិច្ចប្រជុំបូកសរុបប្រចាំខែកក្កដា និងលើកទិសដៅខែសីហា ឆ្នាំ២០២៣*

# ឯកឧត្តម អ៊ុំ សារឹទ្ធ ណែនាំដល់និស្សិតជ័យលាភីអាហារូបករណ៍ JDS ឱ្យគោរពច្បាប់ប្រទេស និងសាលា ព្រមទាំងផ្សាយអំពីការអភិវឌ្ឍប្រទេសជាតិ



*ឯកឧត្តម អ៊ុំសារឹទ្ធ សំណេះសំណាលជាមួយក្រុមនិស្សិត ជ័យលាភីអាហារូបករណ៍ JDS*

នាព្រឹកថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានណែនាំដល់ក្រុម និស្សិតជ័យលាភីអាហារូបករណ៍ JDS ចំនួន២៦រូប ត្រូវគោរពច្បាប់ប្រទេស ច្បាប់សាលាឱ្យបានខ្ជាប់ខ្ជួន ដើម្បីបង្ហាញអំពី សេចក្តីថ្លៃថ្នូរក្នុងនាមជាកូនខ្មែរ ឱ្យក្រុមនិស្សិតដែលមកពីបណ្តាប្រទេសនានាបានឃើញ ត្រូវសម្របខ្លួនរៀនរស់នៅ រៀនទំនាក់ទំនងជាមួយនឹងប្រជាពលរដ្ឋខ្មែរដែលរស់នៅក្នុងប្រទេសជប៉ុន និងនិស្សិតផ្សេងៗទៀតដែលកំពុងសិក្សានៅទីនោះស្រាប់ ព្រមទាំងផ្សព្វផ្សាយអំពីសភាពការណ៍ថ្មីៗ ការអភិវឌ្ឍថ្មីៗរបស់ប្រទេសកម្ពុជាបច្ចុប្បន្ន ដើម្បីទាក់ទាញឱ្យពួកគាត់មកធ្វើទេសចរណ៍នៅប្រទេសកម្ពុជា។

ក្នុងនាមសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឯកឧត្តម **អ៊ុំ សារឹទ្ធ** បានសម្តែងនូវការអបអរសាទរចំពោះក្រុមនិស្សិតជ័យលាភីទាំង២៦រូប ដែលទៅសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៅតាមសកលវិទ្យាល័យនានា នៃប្រទេសជប៉ុន ដែលនេះជាឱកាសមួយដ៏ល្អប្រសើរក្រៃលែង ដែលក្មួយៗនឹងទទួលបាននូវចំណេះដឹងថ្មីៗ ដើម្បីពង្រឹងសមត្ថភាពខ្លួនសម្រាប់ជាមូលដ្ឋានក្នុងការអភិវឌ្ឍខ្លួនផង និងប្រទេសជាតិ។ ជាមួយគ្នានោះ ឯកឧត្តមបានផ្តាំផ្ញើដល់និស្សិតទាំងអស់ថា ទោះបីជាក្មួយៗត្រូវទៅសិក្សានៅសាលាផ្សេងៗគ្នាក៏ពិតមែន ប៉ុន្តែក្មួយៗត្រូវចេះសាមគ្គីភាពផ្ទៃក្នុង សហការគ្នា ទំនាក់ទំនងគ្នា និងចេះជួយយកអាសាគ្នាទៅវិញទៅមក ក្នុងនាមជាខ្មែរដូចគ្នា ដូចសុភាសិតខ្មែរ





*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល*



ទិដ្ឋភាពក្នុងពិធីសំណេះសំណាល

យើងពោលថា នៅផ្ទះម្ដាយទីទៃ នៅព្រៃម្ដាយតែមួយ។

ក្នុងឱកាសនោះ លោក **ចេខ គីមអូន** តំណាងនិស្សិតជ័យលាភី បានថ្លែងចំណាប់អារម្មណ៍ និងអរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះឯកឧត្ដមអគ្គលេខាធិការព្រឹទ្ធសភា ដែលបានអនុញ្ញាតឱ្យក្រុមនិស្សិតបានចូលជួបសំណេះសំណាល និងទទួលបាននូវអនុសាសន៍ដ៏មានតម្លៃ និងបានប្ដេជ្ញាចិត្តខិតខំសិក្សារៀនសូត្រ ដើម្បីទទួលបានចំណេះដឹង និងបទពិសោធន៍ល្អៗ និងរួមចំណែកយ៉ាងសកម្មក្នុងការតភ្ជាប់ទំនាក់ទំនងរវាងប្រជាជន និងប្រជាជន ក៏ដូចជារវាងប្រទេសទាំងពីរកម្ពុជា-ជប៉ុន ឱ្យកាន់តែជិតស្និទ្ធ និងស៊ីជម្រៅថែមទៀត។

សូមជម្រាបថា ក្រុមនិស្សិតជ័យលាភីអាហារូបករណ៍ JDS ឆ្នាំ២០២៣ មានមន្ត្រីរាជការថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងនិស្សិតសរុបចំនួន២៦នាក់ ដែលនឹងត្រូវសិក្សាលើមុខជំនាញចំនួន៨ រួមមាន៖

១-អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ
២-អភិវឌ្ឍន៍វិស័យឯកជន
៣-លើកកម្ពស់គុណភាពអប់រំ
៤-អភិវឌ្ឍន៍កសិកម្ម និងអភិវឌ្ឍន៍ជនបទ
៥-លើកកម្ពស់បរិស្ថានរស់នៅទីក្រុង
៦-លើកកម្ពស់ប្រព័ន្ធថែទាំសុខភាព និងសន្តិសុខសង្គម
៧-លើកកម្ពស់មុខងាររដ្ឋបាលសាធារណៈ
៨-ការកសាងទំនាក់ទំនងអន្តរជាតិ៕

(អត្ថបទ៖ អ៊ុក ប៉ូលីន រូបភាព៖ គង់ យ៉ារីន)





ឯកឧត្ដម អ៊ុំ សារឹទ្ធ ថតរូបអនុស្សាវរីយ៍ជាមួយនិស្សិតជ័យលាភីអាហារូបករណ៍ JDS

# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រជុំផ្សព្វផ្សាយ ការត្រៀមខ្លួនរបស់ព្រឹទ្ធសភា ដើម្បីចូលនីតិកាលថ្មី




*ឯកឧត្តម ឡោក ឆាយ ឯកឧត្តម អ៊ុំសារឹទ្ធ ឯកឧត្តម លឹម ប៊ុនហុក*

នាព្រឹកថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយស្តីពី ការត្រៀមខ្លួនរបស់ព្រឹទ្ធសភា ដើម្បីចូលនីតិកាលថ្មី ក្រោមអធិបតីភាពឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចាប់ពីអនុប្រធាននាយកដ្ឋានឡើង។

មានប្រសាសន៍ក្នុងឱកាសនោះ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានជម្រាបអំពីគោលបំណងនៃការរៀបចំពិធីនេះឡើង ដើម្បីបង្ហាញអំពីបទពិសោធន៍របស់សភា នៃប្រទេសប្រើប្រាស់ប្រព័ន្ធ Commonwealth ស្តីពីការត្រៀមខ្លួនផ្លាស់ប្តូរចូលសភានីតិកាលថ្មី និងការណែនាំសម្រាប់សភាក្នុងការធ្វើផែនការ។ ជាមួយគ្នានោះ ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា ក៏បានជម្រាបអំពីបទពិសោធន៍ នៃការអនុវត្តការងារកន្លងទៅរបស់ព្រឹទ្ធសភាកម្ពុជា ក្នុងការត្រៀមខ្លួនដើម្បីទទួលនីតិកាលថ្មីផងដែរ។

ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាបានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា បានទាន់ពេលវេលា និងល្អប្រសើរ ចាប់តាំងពីនីតិកាលទី១ រហូតដល់នីតិកាលទី៤ ហើយអ្វីដែលត្រូវយកចិត្តទុកដាក់សម្រាប់នីតិកាលថ្មីនាពេលខាងមុខ គឺទាមទារឱ្យថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាទាំងអស់ត្រូវខិតខំលើកកម្ពស់សមត្ថភាពចំណេះដឹងរបស់ខ្លួនបន្ថែមទៀត ដើម្បីផ្តល់សេវាឱ្យកាន់តែល្អ ពូកែ និងលឿនជាងមុន។

ក្នុងឱកាសនោះដែរ តំណាងអគ្គនាយកដ្ឋានស្រាវជ្រាវបានអញ្ជើញធ្វើបទបង្ហាញជូនអង្គពិធីអំពី បទពិសោធន៍របស់សភា នៃប្រទេសប្រើប្រាស់ប្រព័ន្ធ Common wealth ស្តីពីការត្រៀមខ្លួនផ្លាស់ប្តូរចូលសភានីតិកាលថ្មី និងការណែនាំសម្រាប់សភាក្នុងការធ្វើផែនការ ដោយផ្តោតសំខាន់លើ៖

**១-សភា និងការបោះឆ្នោត ការពិចារណាសំខាន់ៗមួយចំនួន**
**២-ការធ្វើផែនការសម្រាប់ពេលខាងមុខឱ្យបានមុន**
**៣-ការគាំទ្រដល់ការបោះឆ្នោត**
**៤-អំឡុងពេលបោះឆ្នោត**
**៥-បន្ទាប់ពីការបោះឆ្នោត**
**៦-ការណែនាំតម្រង់ទិស និងការបណ្តុះបណ្តាល**
**៧-ការវាយតម្លៃ៕**

(អត្ថបទ៖ វង់ សុជាតិ រូបភាព៖ គឹម សិទ្ធី)





*ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមប្រជុំផ្សព្វផ្សាយអំពី ការត្រៀមខ្លួនរបស់ព្រឹទ្ធសភា ដើម្បីចូលនីតិកាលថ្មី*

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នារសៀលថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់អនុវត្តនាពេលខាងមុខ ដោយមានការអញ្ជើញចូលរួមពីឯកឧត្តមអគ្គលេខាធិការរងព្រឹទ្ធសភា ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានទាំង៥ និងថ្នាក់ដឹកនាំនៃអង្គភាពពាក់ព័ន្ធ នៅសាលប្រជុំពិសេសកណ្ដាល វិមានព្រឹទ្ធសភា។



❈នាថ្ងៃទី២៦ និងថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំបន្តការកសាងឯកសារគោលសំខាន់ៗសម្រាប់ព្រឹទ្ធសភា នីតិកាលទី៥ ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអង្គភាពពាក់ព័ន្ធ នៅសាលប្រជុំពិសេសខាងក្រោម វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី១ ខែសីហា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំស្ដីពី ការកែសម្រួលរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីឯកឧត្តមអគ្គលេខាធិការរងព្រឹទ្ធសភា ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានទាំង៥ និងអង្គភាពពាក់ព័ន្ធ នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី១ ខែសីហា ឆ្នាំ២០២៣ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំពិនិត្យ កែសម្រួលគោលការណ៍ ស្ដីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និ៏ងមុខតំណែងគ្រប់គ្រង នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ អគ្គនាយក អគ្គនាយិកា នៃអគ្គនាយកដ្ឋានទាំង៥ និងអង្គភាពពាក់ព័ន្ធ នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៣ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តសមាគមបេសកកម្មមនុស្សធម៌ នៃប្រទេសបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា ចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅក្នុងភូមិខ្វរ សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។



## សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នារសៀលថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៣ ឯកឧត្តម **ឈឹម សុទ្ធគុណ** អគ្គនាយកពិធីការ និងទំនាក់ទំនងអន្តរជាតិ បានទទួលជួបពិភាក្សាការងារជាមួយលោក Wu Chuanbing ទីប្រឹក្សាស្ថានទូតសាធារណរដ្ឋប្រជាមានិតចិនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នៅសាលប្រជុំពិសេសកណ្ដាល វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៣ ឯកឧត្តម **ទេព ចាន់អុនឧធីរក្ស** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ បានជួបប្រជុំជាមួយនឹងតំណាងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ មជ្ឈមណ្ឌលសភាអាស៊ីសមាគមចិន និងអង្គភាពពាក់ព័ន្ធ ដើម្បីពិភាក្សាលើការងារសន្តិសុខផ្ទៃក្នុងបរិវេណព្រឹទ្ធសភា នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៣ លោកជំទាវ **សាយ ចាន់ណាក់** នាយិការងខុទ្ទកាល័យសម្ដេចប្រធានព្រឹទ្ធសភា បានអញ្ជើញនាំយកសាររំលែកទុក្ខ និងថវិការបស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងលោកជំទាវ ចូលរួមរំលែកទុក្ខជាមួយនឹងក្រុមគ្រួសារសព និងគោរពវិញ្ញាណក្ខន្ធសពឧបាសិកា **សែន សុគន្ធ** ម្ដាយក្មេករបស់ឯកឧត្តមសន្តិបណ្ឌិត **សុខ ផល** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅសង្កាត់ផ្សារដើមស្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ។



❈នារសៀលថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៣ លោកជំទាវ **សាយ ចាន់ណាក់** នាយិការងខុទ្ទកាល័យសម្ដេចប្រធានព្រឹទ្ធសភា បានអញ្ជើញនាំយកសាររំលែកទុក្ខ និងថវិការបស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងលោកជំទាវ ចូលរួមរំលែកទុក្ខជាមួយនឹងក្រុមគ្រួសារសព និងដាក់កួរោនផ្កាគោរពវិញ្ញាណក្ខន្ធសពឧបាសិកា **កែវ ណាន** ម្ដាយរបស់ឯកឧត្តម **សាវ៉ាត់ ខាន់** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នៅវត្តលង្កាព្រះហកុសុមារាម (ហៅវត្តសង្កា) រាជធានីភ្នំពេញ៕




ព្រឹទ្ធសភា
SENAT/SENATE